ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកំពង់ឆ្នាំង

សាលក្រមលេខ ៦៦ (ង)

ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៣

# សាលក្រម

## ក្នុងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តកំពង់ឆ្នាំង

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២៣

**ដោយមានសមាសភាព**

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ជាចៅក្រមសាលាដំបូងខេត្តកំពង់ឆ្នាំង

**តំណាងអយ្យការ**

លោក [redacted] ជាព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង

**ក្រឡាបញ្ជី**

លោក [redacted] ជាក្រឡាបញ្ជីនៃសាលាដំបូងខេត្តកំពង់ឆ្នាំង

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ៖ ៨៥៥ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២១ ដែលមានជនជាប់ចោទ៖

១. ឈ្មោះ [redacted]សុភាព ភេទស្រី អាយុ៤៨ឆ្នាំ ជនជាតិខ្មែរ មានទីកន្លែងកំណើតនៅភូ[redacted] ខេត្តកំពង់ឆ្នាំង និងមានទីលំនៅ[redacted] ខេត្តកំពង់ឆ្នាំង ។ ឪពុកឈ្មោះ [redacted] ឡឿន (ស្លាប់) ម្តាយឈ្មោះ [redacted]យ៉ុង (ស្លាប់) ប្តីឈ្មោះ [redacted]បូណា (រស់) មានកូនចំនួន ០២នាក់ ។ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការពីមុន៖ គ្មាន ។

២. ឈ្មោះ [redacted] វិចិត្រា ភេទប្រុស កើតនៅឆ្នាំ១៩៨៦ ជនជាតិខ្មែរ មានទីកន្លែងកំណើតនៅភូ[redacted] ខេត្តកំពង់ឆ្នាំង និងមានទីលំនៅបច្ចុប្បន្ននៅភូ[redacted] ខេត្តកំពង់ឆ្នាំង ។ ឪពុកឈ្មោះ [redacted] បូណា(រស់) ម្តាយឈ្មោះ[redacted]ុភាព(រស់) ប្រពន្ធឈ្មោះ [redacted]ម៉ាលីស (រស់) មានកូនចំនួន០១នាក់ ។ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការពីមុន៖ គ្មាន ។

ជាប់ចោទពីបទ៖**ធ្វើឱ្យខូចខាតដោយចេតនា** បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤១០ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅភូមិដំណាក់ពពូល សង្កាត់កំពង់ឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២១ ។

លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សុភាព ។

លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សុភាព និងឈ្មោះ [redacted] វិចិត្រា ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចិត្រា ហៅ បារាំង ភេទប្រុស អាយុ២៣ឆ្នាំ ជនជាតិខ្មែរ មានទីកន្លែងកំណើតនៅភូមិផ្សារលើ សង្កាត់ផ្សារឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង និងមានទីលំនៅបច្ចុប្បន្ននៅភូមិផ្សារលើ សង្កាត់ផ្សារឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ។ ឪពុកឈ្មោះ [redacted] សុផាត (ស្លាប់) ម្តាយឈ្មោះ [redacted] ស្រីគា (រស់) នៅលីវ ។

- បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់លេខ ៨៧៥ ដ.ស.ផ. ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង ។

- បានឃើញ ដីកាចាត់តាំងចៅក្រមជំនុំជម្រះផ្ទាល់លេខ ២០៧ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០២២ របស់ប្រធានសាលាដំបូងខេត្តកំពង់ឆ្នាំង ។

## អង្គហេតុដែលឆ្លងមកតុលាការ

កាលពីថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២១ មានឈ្មោះ [redacted] សុភាព ភេទស្រី អាយុ៤៨ឆ្នាំ ជនជាតិខ្មែរ និងឈ្មោះ [redacted] វិចិត្រា ភេទប្រុស អាយុ២៦ឆ្នាំ បានធ្វើសកម្មភាពកាច់បង្គោលរបងដែលឈ្មោះ [redacted] ចិត្រា ភេទប្រុស អាយុ២៣ឆ្នាំ ជនជាតិខ្មែរ បានដាំលើដីស្រែនៅចំណុចបឹងធំ ស្ថិតនៅក្នុងភូមិដំណាក់ពពូល សង្កាត់កំពង់ឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ។

## នាពេលសវនាការ

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចិត្រា បានឆ្លើយថា៖ ឪពុករបស់ខ្ញុំបាទបានកាន់កាប់ និងធ្វើស្រែលើដីចំនួន០២កន្លែង នៅចំណុចបឹងធំ ស្ថិតនៅក្នុងភូមិដំណាក់ពពូល សង្កាត់កំពង់ឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ដែលដី០១(មួយ)កន្លែង មានទំហំក្បាលដី ៣៦(សាមសិបប្រាំមួយ)ម៉ែត្រ និងបណ្តោយ ៤០(សែសិប)ម៉ែត្រ និង ០១(មួយ)កន្លែងទៀត មានទំហំក្បាលដី ៥០(ហាសិប)ម៉ែត្រ និងបណ្តោយ១១៥(មួយរយដប់ប្រាំ)ម៉ែត្រ ដោយពួកគាត់ធ្វើស្រែជារៀងរាល់ឆ្នាំ ។ លុះដល់ឆ្នាំ២០១៣ ឪពុកម្តាយរបស់ខ្ញុំបាទបានលែងលះគ្នា ហើយតុលាការបានសម្រេចប្រគល់ដីស្រែមួយកន្លែងឱ្យឪពុកខ្ញុំបាទ ដែលមានទំហំ៤០(សែសិប)ម៉ែត្រ គុណនឹង៥០(ហាសិប)ម៉ែត្រ នៅចំណុចបឹងធំ និងឱ្យខ្ញុំរស់នៅជាមួយឪពុកខ្ញុំបាទ ហើយឪពុកខ្ញុំបាទបានជួលដីស្រែខាងលើនេះឱ្យគេ ។ លុះដល់ឆ្នាំ២០១៥ ឪពុកខ្ញុំបាទក៏ស្លាប់ទៅ ហើយពេលនោះស្រាប់តែអ៊ុំស្រីខ្ញុំបាទឈ្មោះ [redacted] សុភាព បានហៅខ្ញុំបាទទៅពិភាក្សាជាមួយគាត់រឿងធ្វើចេតិយ៍ឪពុកខ្ញុំបាទ ដោយគាត់ឱ្យខ្ញុំបាទផ្តិតមេដៃលក់ដីឱ្យគាត់ ហើយគាត់ជាអ្នកចាត់ចែងធ្វើចេតិយ៍ឱ្យ និងសន្យាឱ្យប្រាក់ខ្ញុំបាទចំនួន ២.០០០ (ពីរពាន់) ដុល្លារអាមេរិក និង ១.០០០.០០០ (មួយលាន) រៀល ប៉ុន្តែបន្ទាប់ពីផ្តិតមេដៃរួច គឺខ្ញុំបាទមិនបានទទួលប្រាក់នេះទេ ។ លុះដល់ខែមករា ឆ្នាំ២០១៦ ខ្ញុំបាទនៅតែមិនទាន់បានទទួលលុយពីគាត់ ពេលនោះខ្ញុំក៏បដិសេធមិនលក់ដីនេះឱ្យគាត់វិញ រហូតដល់ខែមេសា ឆ្នាំ២០១៦



Scanned with CamScanner

ឈ្មោះ [redacted] សុភាព បានទៅយកស្រូវពីអ្នកជួលដីពីឪពុកខ្ញុំបាទ ទើបខ្ញុំក៏តែទៅសួរគាត់ ហើយគាត់បែរជាប្រាប់ថា ដីនេះជាដីរបស់លោកតា [redacted] ខឿន មិនមែនជាដីរបស់ឪពុកខ្ញុំបាទទេ ។ លុះដល់ថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១ ជីតាឈ្មោះ [redacted] ខឿន ក៏ស្លាប់ ខ្ញុំក៏បានប្រាប់អ្នកជួលដីពីឪពុកខ្ញុំបាទនោះថា ខ្ញុំបាទឈប់ជួលឲ្យហើយ ដោយខ្ញុំបាទចាប់ផ្តើមធ្វើស្រែខ្លួនឯងវិញ នៅថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២១ ដោយខ្ញុំបាទបានឲ្យភ្ជួររាស់ដី ហើយមិនមានអ្នកណាទៅហាមឃាត់ឡើយ ។ ដល់ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២១ ខ្ញុំបាទក៏ទៅបោះបង្គោលចំនួន០៨(ប្រាំបី)ដើម លើដីស្រែខាងលើនេះ ហើយនៅថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២១ ស្រាប់តែលឺអ្នកនៅក្បែរនោះ បាននិយាយថា ឈ្មោះ [redacted] សុភាព បានទៅរើបំបាក់បង្គោលរបស់ខ្ញុំបាទអស់ចំនួន០៤(បួន)ដើម ទើបខ្ញុំបាទទៅឃើញក៏បានទូរស័ព្ទទៅប្រាប់ម្តាយខ្ញុំបាទ ។ ខ្ញុំបាទសំណូមពរតុលាការ មេត្តាជួយរកយុត្តិធម៌ឲ្យខ្ញុំបាទផង និងសុំទាមទារសំណងជម្ងឺចិត្ត ចំនួន ៤០.០០០.០០០ (សែសិបលាន) រៀល ។

- អំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សុភាព បានឆ្លើយថា៖ នាងខ្ញុំមិនបានប្រព្រឹត្តដូចការចោទប្រកាន់របស់ឈ្មោះ [redacted] ចិត្រា នោះទេ ។ នាងខ្ញុំសូមបញ្ជាក់ថា នៅឆ្នាំ២០១៣ ពេលដែលប្អូនប្រុសនាងខ្ញុំឈ្មោះ [redacted] សុផាត បានលែងលះជាមួយឈ្មោះ [redacted] ស្រីគា ឪពុកនាងខ្ញុំបានប្រគល់ដី០១(មួយ)កន្លែង ទំហំ៥០(ហាសិប) ម៉ែត្រ គុណនឹង ១១២ (មួយរយដប់ពីរ) ម៉ែត្រ នៅចំណុចបឹងធំ ស្ថិតក្នុងភូមិដំណាក់ពពូល សង្កាត់កំពង់ឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ដើម្បីអាស្រ័យផល ដោយបានជួលដីនេះឲ្យទៅឈ្មោះ សុភ័ស្ស ។ បន្ទាប់មកនៅក្នុងឆ្នាំ២០១៥ ឈ្មោះ [redacted] សុផាត ក៏ស្លាប់ ឪពុកនាងខ្ញុំក៏បានកាន់កាប់ដីខាងលើនេះវិញ ហើយអ្នកដែលជួលដីនោះ ក៏បានយកលុយថ្លៃជួលដីនេះមកឲ្យឪពុកនាងខ្ញុំរហូត ហើយខ្ញុំក៏បានហៅឈ្មោះ [redacted] ចិត្រា មកពិភាក្សារឿងធ្វើចេតិយឲ្យឪពុកវាឈ្មោះ [redacted] សុផាត និងឲ្យប្រាក់ចំនួន ២.០០០(ពីរពាន់) ដុល្លារអាមេរិក ទៅឈ្មោះ [redacted] ចិត្រា ហើយឈ្មោះ [redacted] ចិត្រា បានព្រមផ្ទេរកម្មសិទ្ធិដីខាងលើ ដែលតុលាការបានសម្រេចប្រគល់ឲ្យឪពុកវាឈ្មោះ [redacted] សុផាត មានទំហំ ៤០ (សែសិប) ម៉ែត្រ គុណនឹង ៥០ (ហាសិប) ម៉ែត្រ នៅចំណុចបឹងធំ ស្ថិតក្នុងភូមិដំណាក់ពពូល សង្កាត់កំពង់ឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង នោះមកឲ្យនាងខ្ញុំវិញ ប៉ុន្តែក្រោយមកឈ្មោះ [redacted] ចិត្រា បែរជាប្រកែកមិនព្រមផ្ទេរកម្មសិទ្ធិមកឲ្យនាងខ្ញុំទៅវិញ ។ ក្រោយមកនៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០២១ ឪពុកនាងខ្ញុំក៏ស្លាប់ទៅ នាងខ្ញុំមើលការខុសត្រូវលើដីខាងលើនេះបន្តពីគាត់ ហើយនៅចុងខែឧសភា ឆ្នាំ២០២១ នាងខ្ញុំបានឃើញគេភ្ជួររាស់ដីស្រែខាងលើនេះ ប៉ុន្តែមិនដឹងថា អ្នកណាជាអ្នកភ្ជួរនោះទេ ។ បន្ទាប់មកទៀត នាងខ្ញុំបានឃើញឈ្មោះ ខឿន ចិត្រា ដាំបង្គោលរបងលើដីខាងលើនេះ ពេលនោះនាងខ្ញុំក៏បានទៅប្រាប់ កុំឲ្យដាំបង្គោលលើដីនេះ ព្រោះជាដីរបស់នាងខ្ញុំ ហើយឈ្មោះ [redacted] ចិត្រា បាននិយាយថា ជាដីរបស់ឪពុកគាត់ រួចខ្ញុំក៏ប្រាប់ថា ទោះជាដីរបស់អ្នកណាក៏ដោយក៏កុំទាន់ដាំ ព្រោះដីនេះមានដីការក្សាការពារពីតុលាការ តែឈ្មោះនេះនៅតែដាំ ។ ចំពោះពាក្យចោទប្រកាន់របស់ឈ្មោះ [redacted] ចិត្រា ថានាងខ្ញុំបានរើបំបាក់បង្គោលរបងដែលគាត់បានដាំនោះ គឺនាងខ្ញុំសុំបដិសេធទាំងស្រុង ព្រោះនាងខ្ញុំមិនបានប្រព្រឹត្តដូចការចោទប្រកាន់នេះទេ ។ ដីខាងលើនេះឪពុករបស់នាងខ្ញុំ បានទិញបានទិញពីគេម្តង

បន្តិចៗ និងកាប់ឆ្ការខ្លួនឯងខ្លះ តាំងពីឆ្នាំ១៩៩៣ មកម្ល៉េះ ដោយបានធ្វើលិខិតលក់ទិញដី ប៉ុន្តែមិនមានប័ណ្ណកម្មសិទ្ធិនោះទេ ។

- អំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] វិចិត្រា បានឆ្លើយថា៖ ក្រោយពីឪពុកមាខ្លួនស្លាប់ទៅ ខ្លួនបានទៅមើលដីស្រែប្រាំងជាមួយជីតាខ្លួនឈ្មោះ [redacted] ឌឿន ដីនៅចំណុចបឹងធំ ស្ថិតក្នុងភូមិដំណាក់ពពូល បាន០១(មួយ)ដង ដីនោះ គឺជាដីដែលមានទំនាស់ជាមួយឈ្មោះ [redacted] ស្រីគា និងឈ្មោះ [redacted] ចិត្រា ហើយពេលខ្លួនទៅមើលដីស្រែប្រាំងនោះ ខ្លួនឃើញមានបង្គោលស៊ីម៉ង់ត៍ខ្លី ០១(មួយ)ដើម បោះលើព្រំនៅជ្រុងខាងត្បូងផ្នែកខាងលិច ចាប់តាំងពីពេលនោះមក ខ្លួនពុំដែលបានទៅមើលទៀតទេ ។ ក្រៅពីនេះ ខ្លួនពុំបានដឹងអ្វីទាំងអស់ ។

- សាក្សីឈ្មោះ [redacted] ស្រីគា បានឆ្លើយថា៖ នៅថ្ងៃទី០១ និងថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២១ វេលាម៉ោងប្រហែល១៣ និង៣០នាទី នាងខ្ញុំបានទៅដល់ស្រែ ហើយក៏ឃើញបង្គោលនៅលើដីស្រែកូនរបស់ខ្លួន បានបាក់អស់ចំនួនបួនដើម ហើយនាងខ្ញុំក៏បានសួរទៅអ្នកដែលនៅជិតនោះ មានឈ្មោះ [redacted] គឹមរឿន និងអ្នកជីកដីក្បែរនោះ ទើបពួកគេបានប្រាប់ថា ឃើញបងថ្លៃរបស់នាងខ្ញុំឈ្មោះ [redacted] សុភាព ជាអ្នកវាយ ។ ដល់ថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២១ វេលាម៉ោង០៨ និង០០នាទី នាងខ្ញុំក៏បានទៅប្តឹងនៅស្នងការនគរបាលខេត្តកំពង់ឆ្នាំង ហើយដល់ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២១ វេលាម៉ោង១៤ និង០០នាទី ឈ្មោះ [redacted] សុភាព បានទៅរករឿងកូនប្រុសរបស់នាងខ្ញុំដល់ដីស្រែរបស់វាថែមទៀតផង ។

- សាក្សីឈ្មោះ [redacted] សោភ័ណ្ឌ បានឆ្លើយថា៖ ចំពោះរឿងដក និងបំផ្លិចបំផ្លាញបង្គោលរបងនោះ គឺខ្លួនមិនបានដឹងនោះទេ ខ្លួនដឹងតែថា នៅឆ្នាំ២០០១ គឺខ្លួន និងប្រពន្ធបានធ្វើស្រែប្រាំងនៅខាងលើទំនប់បឹងធំ ហើយខ្លួនបានឃើញឈ្មោះ [redacted] សុផាត និងប្រពន្ធឈ្មោះ [redacted] ស្រីគា ធ្វើស្រែប្រាំងនៅជិតនោះចំនួន ០២(ពីរ) ស្រែ រីឯឈ្មោះ [redacted] ត សុភាព និងប្តី គឺមិនដែលឃើញទៅធ្វើស្រែម្តងណាទេ ។ ខ្លួនសូមបញ្ជាក់ថា ដីស្រែប្រាំងទាំង០២(ពីរ)កន្លែង ដែលនៅជាប់នឹងដីរបស់ខ្លួននៅម្តុំលើទំនប់បឹងធំ គឺពិតជាដីរបស់ឈ្មោះ [redacted] សុផាត និងប្រពន្ធឈ្មោះ [redacted] ស្រីគា ។ ចំណែកឈ្មោះ [redacted] ឌឿន គាត់បានធ្វើស្រែចំនួន០២(ពីរ)កន្លែងផ្សេងទៀត ។

- សាក្សីឈ្មោះ [redacted] កុសល បានឆ្លើយថា៖ ចំពោះរឿងដក និងបំផ្លិចបំផ្លាញបង្គោលរបងនោះ គឺខ្លួនមិនបានដឹងនោះទេ គឺខ្លួនដឹងតែថា កាលពីថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៥ វេលាម៉ោងប្រហែល ១០ និង០០នាទី ព្រឹក ខ្លួននៅផ្ទះ ស្រាប់តែឃើញឈ្មោះ [redacted] ឌឿន, ឈ្មោះ [redacted] សុវណ្ណ, ឈ្មោះ [redacted] សោភ័ណ្ឌ, ឈ្មោះ [redacted] សុភាព ឈ្មោះ [redacted] ល័ក្ខណា និងលោកក្មួយឈ្មោះ [redacted] ចិត្រា មកដល់ ហើយឡើងមកលើផ្ទះខ្លួន។ ពេលនោះឈ្មោះ [redacted] សុភាព បានពឹងខ្លួនឱ្យសរសេរកិច្ចសន្យាពីរឿងលុយធ្វើចេតិយ៍ដាក់ឆ្អឹងសពរបស់ឈ្មោះ [redacted] សុផាត ដោយការសង់ចេតិយ៍អស់លុយច្រើន ទើបឈ្មោះ [redacted] សុភាព សុំយកដីស្រែចំនួន ០២(ពីរ)កន្លែង របស់ឈ្មោះ [redacted] សុផាត នៅឯទំនប់បឹងធំ ក្នុងភូមិដំណាក់ពពូល ហើយឈ្មោះ [redacted] សុភាព សន្យាឱ្យលុយចំនួន ២.០០០(ពីរពាន់) ដុល្លារ ទៅលោកក្មួយឈ្មោះ [redacted] ចិត្រា មុនធ្វើចេតិយ៍ ។ ចំពោះលុយ ២.០០០ (ពីរពាន់)ដុល្លារនេះ ឈ្មោះ [redacted] សុភាព បានឱ្យ ឬមិនបានឱ្យទៅលោកក្មួយឈ្មោះ [redacted] ចិត្រា នោះ គឺខ្លួនពុំបានដឹងទេ ។ រីឯកិច្ចសន្យាវិញ គឺខ្លួនជាអ្នកសរសេរ



Scanned with CamScanner

ផ្ទាល់ដៃតាមការព្រមព្រៀងរវាងឈ្មោះ [redacted] សុភាព និងលោកក្មួយឈ្មោះ [redacted] ចិត្រា ពុំមែនឈ្មោះ [redacted] ល័ក្ខណា ជាអ្នកសរសេរនោះទេ ។ ចំណែកឯចេតិយ៍ គឺបានសង់រួចដោយឈ្មោះ [redacted] សុភាព ត្រង់ថាគាត់យកលុយពីអ្នកណាមកសង់ គឺខ្លួនពុំបានដឹងទេ ។

- សាក្សីឈ្មោះ [redacted] ល័ក្ខណា បានឆ្លើយថា៖ កាលពីថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៥ ខ្លួនបានទៅធ្វើបុណ្យជាមួយបងប្អូននៅផ្ទះឈ្មោះ [redacted]ន ក្នុងភូមិត្រងិល ពេលធ្វើបុណ្យចប់នៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៥ ចន្លោះម៉ោង១១ ទៅ១៤ ជីតាខ្លួនឈ្មោះ [redacted] ឌឿន បានហៅម្តាយខ្លួន, រូបខ្លួន, ឈ្មោះ [redacted] សុវណ្ណ, ឈ្មោះ [redacted] សោភ័ណ្ឌ, ឈ្មោះ [redacted] កុសល និងឈ្មោះ [redacted] ចិត្រា ពិភាក្សាពីរឿងធ្វើចេតិយ៍ដាក់ឆ្អឹងសពរបស់ឈ្មោះ [redacted] សុផាត ព្រោះមុនពេលគាត់ស្លាប់គាត់ផ្តាំឱ្យជួយធ្វើចេតិយ៍ដាក់ឆ្អឹងគាត់ផង ។ ក្រោយពេលពិភាក្សា ជីតាខ្លួនឈ្មោះ [redacted] ឌឿន បានប្រគល់ដីស្រែប្រាំងរបស់គាត់ដែលឈ្មោះ [redacted] សុផាត ធ្វើស្រែកាលនៅរស់ ក្នុងភូមិដំណាក់ពពូល ឱ្យមកម្តាយខ្លួនទំហំ ៤០(សែសិប)ម៉ែត្រ គុណនឹង ៥០(ហាសិប)ម៉ែត្រ ហើយឱ្យម្តាយខ្លួនប្រគល់លុយ ២.០០០ (ពីរពាន់) ដុល្លារ ឱ្យទៅឈ្មោះ [redacted] ចិត្រា ហើយឈ្មោះ [redacted] ចិត្រា ក៏បានយល់ព្រម ក៏បានធ្វើកិច្ចសន្យា តែក្នុងពេលនោះម្តាយខ្លួនពុំបានប្រគល់លុយឱ្យឈ្មោះ [redacted] ចិត្រា នោះទេ ។ ក្នុងឆ្នាំ២០១៦ ឈ្មោះ [redacted] ចិត្រា បែរជាមិនព្រមលក់ដីនោះវិញ រីឯចេតិយ៍ម្តាយខ្លួនក៏បានធ្វើរួចហើយដែរ ។

- អំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] គឹមរឿន បានឆ្លើយថា៖ កាលពីឆ្នាំ១៩៨២ ខ្លួន និងប្តីនាំគ្នាទៅស្រែប្រាំងរបស់ខ្លួននៅចំណុចទំនប់ទួលអំពិល ក្នុងភូមិដំណាក់ពពូល ពេលនោះខ្លួន និងប្តីបានជួលដីអ្នកនៅជិតនោះធ្វើស្រែបន្ថែម ។ ពេលខ្លួន និងប្តីធ្វើស្រែប្រាំងទីនោះ ខ្លួនឃើញឈ្មោះ [redacted] និងឈ្មោះ [redacted]សុផាត ធ្វើស្រែនៅជិតនោះចំនួន០២(ពីរ)ស្រែ ពេលនោះខ្លួនឃើញឈ្មោះ [redacted] ស្រីគា យកបាយមកឱ្យប្តីឈ្មោះ [redacted] សុផាត និងឪពុកក្មេកឈ្មោះ [redacted] ហួប ពេលខ្លះឈ្មោះ ឱត សុផាត យកបាយពីផ្ទះមកជាមួយស្រេច ។ ចំណែកឈ្មោះ [redacted]សុភាព ខ្លួនមិនដែលស្គាល់ទេ ហើយក៏មិនដែលឃើញមកធ្វើស្រែប្រាំងជាមួយឈ្មោះ [redacted] នោះទេ ។ ដល់ឆ្នាំ២០១៨ ឈ្មោះ ឌឿន បានលក់ដីទាំង០២(ពីរ)កន្លែង ដែលគាត់ធ្លាប់ធ្វើស្រែពីមុន បានប្រហែល០១(មួយ)ឆ្នាំ ឈ្មោះ ឌឿន គាត់មានប្រពន្ធនៅឯឃុំព្រៃមូលបាត់ទៅ ។ ក្នុងឆ្នាំ២០១៨ នោះដែរ ខ្លួនក៏ធ្វើស្រែប្រាំងលែងកើត ខ្លួនក៏ប្រគល់ដីស្រែប្រាំងរបស់ឈ្មោះ [redacted] ស្រីគា ឱ្យទៅឈ្មោះ [redacted]ស្រីគា វិញ ហើយឈ្មោះ [redacted] ស្រីគា បានជួលដីនោះឱ្យអ្នកភូមិម៉ុងបារាំង ជាអ្នកធ្វើបន្ត ។ ពេលខ្លួនជួលដីពីឈ្មោះ [redacted] ស្រីគា ខ្លួនបានឱ្យថ្លៃឈ្នួលទៅគាត់ ហើយខ្លួនឃើញតែកូនប្រុសរបស់ឈ្មោះ [redacted] សុផាត យកបង្គោលស៊ីម៉ង់ត៍ ០៨(ប្រាំបី)ដើម ទៅបោះធ្វើជាព្រំដីសម្គាល់ដីស្រែទាំង២(ពីរ) កន្លែង នៅលើទំនប់របស់ខ្មោចឪពុកវា ។ ដល់ឆ្នាំ២០២១ វេលាម៉ោង១១ និង០០នាទីព្រឹក ខ្លួនទៅស្រែរបស់នៅក្រោយទំនប់ បានឃើញឈ្មោះ [redacted] សុភាព និងក្មេងប្រុសម្នាក់ទៀត និងម៉ូតូ០១(មួយ)គ្រឿង ទុកនៅលើខ្នងទំនប់ទល់មុខដីរបស់ឈ្មោះ [redacted]ស្រីគា ខ្លួនក៏ទៅស្រែប្រាំងរបស់ខ្លួន ដល់ម៉ោង១៧ និង០០នាទី ខ្លួនត្រឡប់មកវិញ ដើរតាមដីរបស់ឈ្មោះ [redacted] ស្រីគា ឃើញបង្គោលព្រំដីរបស់គាត់ទាំង០៤(បួន)ដើម ត្រូវគេវាយបំបាក់ តែខ្លួនមិនដឹងថាអ្នកណាជាអ្នកវាយនោះទេ ។

- អំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] ខុម បានឆ្លើយថា៖ កាលពីក្នុងឆ្នាំ១៩៩៨ ឈ្មោះ ចាន់ ប្រពន្ធឈ្មោះ សឿន បានលក់ដី០១(មួយ)កន្លែងនៅម្តុំរណ្តៅកុងជាប់ទំនប់ទួលអំពិល ស្ថិតក្នុងភូមិដំណាក់ពពូល ដែលមានទំហំ ៣៦(សាមសិបប្រាំមួយ)ម៉ែត្រ គុណនឹង ៤០(សែសិប)ម៉ែត្រ មានព្រំខាងជើងជាប់ដីឈ្មោះ ជាតិ, ឈ្មោះ អុក ខាងកើតជាប់ទំនប់ទួលអំពិល ខាងត្បូងជាប់ដីឈ្មោះ [redacted] ខុម, ឈ្មោះ [redacted]ត ខាងលិចជាប់ដីឈ្មោះ [redacted] ណារី, ឈ្មោះ ម៉ៅ លក់ទៅឲ្យឈ្មោះ [redacted]សុផាត និងប្រពន្ធគាត់ ក្នុងតម្លៃ ៤០០.០០០ (សែសិបម៉ឺន) រៀល ។ ក្រោយពេលឈ្មោះ [redacted] សុផាត និងប្រពន្ធគាត់ឈ្មោះ [redacted] ស្រីគា ទិញដីរួចហើយ ពួកគាត់បានធ្វើស្រែនៅលើដីនោះរហូតមក។

- អំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] សុខា បានឆ្លើយថា៖ កាលពីឆ្នាំ១៩៩៧ ខ្លួនបានលក់ដីស្រែប្រាំង ០១(មួយ)កន្លែង នៅទំនប់ទួលអំពិល ស្ថិតក្នុងភូមិដំណាក់ពពូល (ខ្លួនភ្លេចទំហំ និងព្រំអស់ហើយ) ឲ្យទៅឈ្មោះ [redacted] ឌឿន និងប្រពន្ធឈ្មោះ [redacted]យុំ នៅផ្សារឆ្នាំង ក្នុងតម្លៃ ៥(ប្រាំ)ជីមាស ។ ក្រោយពីខ្លួនលក់ដីរួចហើយ ខ្លួនឃើញឈ្មោះ [redacted] ឌឿន, ឈ្មោះ [redacted] សុផាត និងឈ្មោះ [redacted]ស្រីគា ជាអ្នកធ្វើស្រែនៅលើដីនោះ ។ ចំណែកឈ្មោះ [redacted]សុភាព គាត់មកម្តងម្កាលតែប៉ុណ្ណោះ ។ ហើយដីស្រែប្រាំងនេះ ឈ្មោះ [redacted] ឌឿន គាត់ចែកឲ្យកូនគាត់មួយណានោះ ខ្លួនពុំបានដឹងទេ ប៉ុន្តែខ្លួនដឹងថា ឈ្មោះ [redacted] សុផាត និងប្រពន្ធគាត់ឈ្មោះ [redacted] ស្រីគា ជាអ្នកអាស្រ័យផលនៅលើដីនោះរហូតមក ។

- អំណានចម្លើយរបស់សាក្សីឈ្មោះ [redacted]សុខា បានឆ្លើយថា៖ កាលពីឆ្នាំ២០១៣ ខ្ញុំបាទ និងប្រពន្ធបានជួលដីឈ្មោះ [redacted]សុផាត ភេទប្រុស និងប្រពន្ធឈ្មោះ [redacted]ស្រីគា ដើម្បីធ្វើស្រែប្រាំង ប៉ុន្តែខ្ញុំបាទ និងប្រពន្ធខ្ញុំបាទ មិនដែលបានឃើញ និងមិនស្គាល់ឈ្មោះ [redacted]ស្រីគា នេះទេ ។ ដីនោះនៅចំណុចបឹងធំ (លើទំនប់) មានទំហំ ៧០ (ចិតសិប)អារ ស្ថិតក្នុងភូមិដំណាក់ពពូល សង្កាត់កំពង់ឆ្នាំង ដោយក្នុង០១(មួយ)រដូវ គាត់យកថ្លៃឈ្នួលដីជាស្រូវទម្ងន់ ៦០០(ប្រាំរយ) គីឡូក្រាម ប៉ុន្តែគិតតាមតម្លៃស្រូវតាមទីផ្សារ ។ ដល់ឆ្នាំ២០១៥ ឈ្មោះ [redacted]សុផាត គាត់ក៏ស្លាប់ ហើយឈ្មោះ [redacted] ឌឿន ត្រូវជាឪពុករបស់ឈ្មោះ [redacted] សុផាត បានយកឈ្នួលដីពីខ្ញុំបាទ និងប្រពន្ធបន្តដោយឲ្យកូនស្រីគាត់ឈ្មោះ [redacted]សុភាព មកយកពីពួកខ្ញុំ ។ ដល់ឆ្នាំ២០១៨ ពួកខ្ញុំក៏ឈប់ធ្វើស្រែនោះ ហើយឈ្មោះ [redacted] សុភ័ស្ស ជាអ្នកធ្វើបន្ត ។ ដីដែលខ្ញុំបាទជួលពីឈ្មោះ [redacted]សុផាត ខ្ញុំបាទមិនដឹងថា ជាដីរបស់អ្នកណាទេ ប៉ុន្តែកាលឈ្មោះ [redacted] សុផាត នៅរស់ ក៏គ្មានអ្នកណាមកទារថ្លៃឈ្នួលដីពីពួកខ្ញុំបាទដែរ មានតែឈ្មោះ ផាត ប៉ុណ្ណោះ ។

- អំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] សុភ័ក្រ បានឆ្លើយថា៖ ក្រោយពីនាងខ្ញុំរៀបការជាមួយប្តីនាងខ្ញុំរួចកាលពីឆ្នាំ២០១៣ នាងខ្ញុំ និងប្តី មិនមានមុខរបរសម្រាប់ចិញ្ចឹមជីវិតទេ ហើយបាននាំគ្នាទៅជួលដីស្រែប្រាំងពីឈ្មោះ [redacted] សុផាត នៅម្តុំទំនប់បឹងធំ (ខាងលើទំនប់) ដីមានទំហំ ៧០(ចិតសិប) អារ ស្ថិតនៅក្នុងភូមិដំណាក់ពពូល សង្កាត់កំពង់ឆ្នាំង ដោយក្នុង ០១(មួយ) រដូវ ឈ្មោះ [redacted]សុផាត យកឈ្នួលដីជាស្រូវទម្ងន់ ៦០០ (ប្រាំមួយរយ) គីឡូក្រាម រីឯឈ្មោះ [redacted] សុផាត គាត់រស់នៅភូមិផ្សារលើ សង្កាត់ផ្សារឆ្នាំង ។ កាលពីនាងខ្ញុំជួលដីពីឈ្មោះ [redacted] សុផាត នាងខ្ញុំមិនដែលស្គាល់ប្រពន្ធគាត់ទេ ហើយពេលនោះគ្មានអ្នកណាមកយកថ្លៃឈ្នួលដីពីខ្ញុំក្រៅពីគាត់ឡើយ ។ ដល់ឆ្នាំ២០១៥ ឈ្មោះ [redacted]សុផាត គាត់ក៏បានស្លាប់ទៅ ឈ្មោះ [redacted] ឌឿន ត្រូវជាឪពុកឈ្មោះ [redacted]សុផាត គាត់ក៏



Scanned with CamScanner

បានយកថ្លៃឈ្នួលដីស្រែពីនាងខ្ញុំ និងប្ដីបន្តដោយគាត់ឲ្យកូន និងប្ដី ផ្ញើលុយឲ្យគាត់តាមរយៈកូនស្រីឈ្មោះ [redacted] សុភាព លុះដល់ឆ្នាំ២០១៨ នាងខ្ញុំ និងប្ដីឈប់ធ្វើស្រែ ហើយឈ្មោះ [redacted] សុភ័ស្ស ជួលដីបន្ត ។

- អំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] សុភ័ស្ស បានឆ្លើយថា៖ កាលពីឆ្នាំ២០១៨ ខ្លួនបានធ្វើស្រែប្រាំងនៅចំណុចទួលអំពិល បន្តពីប្អូនស្រីដែលបានជួលដីពីឈ្មោះ [redacted] សុផាត នៅភូមិផ្សារលើ ។ ពេលខ្លួនធ្វើស្រែប្រាំងបន្តពីប្អូន ស្រាប់តែឈ្មោះ [redacted] ឌឿន គាត់ជាឪពុករបស់ឈ្មោះ [redacted] សុផាត មកទារយកថ្លៃឈ្នួលដីពីខ្លួន ដល់ពេលឈ្មោះ [redacted] ឌឿន គាត់ស្លាប់ ខ្លួនក៏ឈប់ធ្វើ ប៉ុន្តែនៅឆ្នាំចុងក្រោយខ្លួនឲ្យលុយថ្លៃឈ្នួលដីទៅឈ្មោះ [redacted] សុភាព បាន០១(មួយ)ដង ។ នៅពេលខ្លួនធ្វើស្រែប្រាំងនៅលើដីស្រែនោះ ខ្លួនបានឃើញបង្គោលស៊ីម៉ងត៍បោះព្រំដីនៅលើដីស្រែប្រាំងទាំង០២(ពីរ)កន្លែង ត្រង់ថាអ្នកណាបោះនោះ ខ្លួនពុំបានដឹងទេ ។ ក្រោយមកខ្លួនឃើញបង្គោលស៊ីម៉ងត៍ដែលបោះព្រំដីនោះ ត្រូវបានគេដកផ្ដួលចោលទៅលើដីស្រែ តែខ្លួនពុំដឹងថាអ្នកណាជាអ្នកដកនោះទេ ។

- អំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] សុវណ្ណ បានឆ្លើយថា៖ នៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៥ ខ្លួន និងប្រពន្ធ និងឈ្មោះ [redacted] សុភាព, ឈ្មោះ [redacted] កុសល, ឈ្មោះ [redacted] សុភី និងឈ្មោះ [redacted] លក្ខ័ណា បានទៅធ្វើបុណ្យនៅផ្ទះឈ្មោះ [redacted] ន ក្នុងភូមិត្រងិល និងបានពិភាក្សាគ្នាពីរឿងធ្វើចេតិយ៍ដាក់ធាតុឈ្មោះ [redacted] សុផាត ពេលនោះឈ្មោះ [redacted] ឌឿន និងឈ្មោះ [redacted] សុភាព បានសួរឈ្មោះ [redacted] ចិត្រា ថាយើងពុំមានលុយធ្វើចេតិយ៍ទេ មានតែចៅឯងលក់ដីរបស់ឪពុកឯងនៅចំណុចបឹងធំ ក្នុងភូមិដំណាក់ពពូល ទំហំ៤០(សែសិប)ម៉ែត្រ គុណនឹង ៥០(ហាសិប) ម៉ែត្រ នោះទៅ ហើយឈ្មោះ [redacted] ចិត្រា ក៏យល់ព្រម តែមិនទទួលលុយនោះទេ ក្រោយមកឈ្មោះ [redacted] ចិត្រា ក៏បានបដិសេធមិនលក់ដីនោះវិញ ។

- តំណាងអយ្យការ បានធ្វើសេចក្ដីសន្និដ្ឋានថា៖ តាមចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ចម្លើយរបស់ជនជាប់ចោទ និងចម្លើយរបស់សាក្សី ព្រមទាំងភស្តុតាងដែលមានក្នុងសំណុំរឿង តំណាងអយ្យការយល់ឃើញថាមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ទៅលើជនជាប់ចោទ ដូចការចោទប្រកាន់មែន ។ ហេតុនេះ តំណាងអយ្យការស្នើសុំចៅក្រមជំនុំជម្រះសម្រេចផ្ដន្ទាទោសជនជាប់ចោទទៅតាមច្បាប់ ដោយសូមតម្កល់ការចោទប្រកាន់ទុកជាបានការដដែល ។

- លោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] សុភាព និងឈ្មោះ [redacted] វិចិត្រា បានធ្វើសេចក្ដីសន្និដ្ឋានថា៖ តាមការពិនិត្យទៅលើចម្លើយរបស់ភាគី និងភស្តុតាង ឃើញថា កូនក្ដីរបស់ខ្ញុំបាទឈ្មោះ [redacted] វិចិត្រា ពុំបានប្រព្រឹត្តបទល្មើសនៅថ្ងៃកើតហេតុនោះទេ ហេតុនេះខ្ញុំបាទស្នើសុំតុលាការឲ្យកូនក្ដីរបស់ខ្ញុំបាទរួចផុតពីការចោទប្រកាន់ ។ ចំពោះកូនក្ដីរបស់ខ្ញុំបាទឈ្មោះ [redacted] សុភាព វិញ ក៏ពុំបានប្រព្រឹត្តនោះដែរ ដោយសារតែពុំមានចម្លើយសាក្សីណាមួយដែលអាចបញ្ជាក់បានថា កូនក្ដីរបស់ខ្ញុំបាទបានប្រព្រឹត្តនោះទេ ដែលនេះជាករណីវិមតិសង្ស័យដែលត្រូវបានជាប្រយោជន៍ដល់កូនក្ដីរបស់ខ្ញុំបាទ ។ ម្យ៉ាងទៀតដីនេះក៏ត្រូវបានតុលាការសម្រេចប្រគល់មកឲ្យកូនក្ដីរបស់ខ្ញុំបាទរួចហើយដែរ គ្រាន់តែសេចក្ដីសម្រេចនោះមិនទាន់ចូលជាស្ថាពរ ។ ហេតុនេះ ខ្ញុំបាទស្នើសុំតុលាការសម្រេចឲ្យកូនក្ដីរបស់ខ្ញុំបាទបានរួចផុតពីបទចោទប្រកាន់ ។



Scanned with CamScanner

- ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី
- ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនជាប់ចោទ
- ក្រោយពីបានស្តាប់ចម្លើយរបស់សាក្សី
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ
- ក្រោយពីបានពិនិត្យឯកសារ និងភស្តុតាងនានា
- ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១. ចំពោះជនជាប់ចោទឈ្មោះ [redacted] សុភាព និងឈ្មោះ [redacted] វិចិត្រា តុលាការយល់ឃើញថា ៖

- តាមចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចិត្រា បានបញ្ជាក់ថា៖ នៅថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២១ ខ្លួនបានទៅបោះបង្គោលចំនួន០៨(ប្រាំបី)ដើម នៅលើដីស្រែរបស់ខ្លួន ហើយក្រោយមកក៏លឺអ្នកនៅក្បែរនោះ បាននិយាយថា ឈ្មោះ [redacted] សុភាព បានទៅវៃបំបាក់បង្គោលរបស់ខ្លួនអស់ចំនួន០៤(បួន)ដើម ទើបខ្លួនទៅឃើញ ក៏បានទូរស័ព្ទទៅប្រាប់ម្តាយ ។ រីឯជនជាប់ចោទឈ្មោះ [redacted] សុភាព បានបញ្ជាក់ថា៖ នៅចុងខែឧសភា ឆ្នាំ២០២១ ខ្លួនបានឃើញគេភ្ជួររាស់ដីស្រែខាងលើ ហើយបន្ទាប់មក ខ្លួនបានឃើញឈ្មោះ [redacted] ចិត្រា ដាំបង្គោលរបងលើដីខាងលើនេះ ពេលនោះខ្លួនក៏បានទៅប្រាប់កុំឲ្យដាំបង្គោលលើដីនេះ ព្រោះជាដីរបស់ខ្លួន ហើយឈ្មោះ [redacted] ចិត្រា បាននិយាយថា ជាដីរបស់ឪពុកគាត់ រួចខ្លួនក៏ប្រាប់ថា ទោះជាដីរបស់អ្នកណាក៏ដោយក៏កុំទាន់ដាំ ព្រោះដីនេះមានដីការក្សាការពារ តែឈ្មោះនេះនៅតែដាំ ហើយខ្លួនមិនបានវៃបំបាក់បង្គោលរបងដែលគាត់បានដាំទេ ។ ចំណែកឯជនជាប់ចោទឈ្មោះ [redacted] វិចិត្រា បានបញ្ជាក់ថា៖ ពេលខ្លួនទៅមើលដីស្រែដែលមានទំនាស់ជាមួយនឹងឈ្មោះ [redacted] ចិត្រា នោះ គឺខ្លួនឃើញមានបង្គោលស៊ីម៉ង់ត៍ខ្លី ០១(មួយ)ដើម បោះលើព្រំនៅជ្រុងខាងត្បូងផ្នែកខាងលិច ហើយចាប់តាំងពីពេលនោះមក ខ្លួនពុំដែលបានទៅមើលទៀតទេ និងពុំបានដឹងអ្វីទាំងអស់ ។

- តាមចម្លើយសាក្សីឈ្មោះ [redacted] មរឿន បានបញ្ជាក់ថា៖ នៅឆ្នាំ២០២១ វេលាម៉ោង១១ និង០០នាទី ព្រឹក ខ្លួនបានទៅស្រែរបស់ខ្លួននៅក្រោយទំនប់ ក៏ឃើញឈ្មោះ [redacted] សុភាព និងក្មេងប្រុសម្នាក់ទៀត និងម៉ូតូ០១(មួយ)គ្រឿង ទុកនៅលើខ្នងទំនប់ទល់មុខដីរបស់ឈ្មោះ [redacted] ស្រីគា រួចខ្លួនក៏ទៅស្រែប្រាំងរបស់ខ្លួន លុះដល់ម៉ោង១៧ និង០០នាទី ខ្លួនត្រឡប់មកវិញ ដើរតាមដីរបស់ឈ្មោះ [redacted] ស្រីគា ក៏ឃើញបង្គោលព្រំដីទាំង០៤(បួន)ដើម ត្រូវគេវាយបំបាក់ ។ ចំណែកឯសាក្សីឈ្មោះ [redacted] ស្រីគា បានបញ្ជាក់ថា៖ នៅថ្ងៃទី០១ និងថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២១ ខ្លួនបានទៅដល់ស្រែ ក៏ឃើញបង្គោលនៅលើដីស្រែកូនរបស់ខ្លួន បានបាក់អស់ចំនួនបួនដើម ហើយខ្លួនក៏បានសួរទៅអ្នកដែលនៅជិតនោះមានឈ្មោះ [redacted] គឹមរឿន និងអ្នកជីកដីក្បែរនោះ ទើបពួកគេប្រាប់ថា ឃើញបងថ្លៃរបស់ខ្លួនឈ្មោះ [redacted] សុភាព ជាអ្នកវាយ ។ រីឯសាក្សីឈ្មោះ [redacted] សុភ័ស្ស បានបញ្ជាក់ថា៖ នៅពេលខ្លួនធ្វើស្រែប្រាំងនៅលើដីស្រែនោះ ខ្លួនបានឃើញបង្គោលស៊ីម៉ង់ត៍បោះព្រំដីនៅលើដីស្រែប្រាំងទាំង ០២(ពីរ) កន្លែង ក្រោយមកខ្លួន



Scanned with CamScanner

ឃើញបង្គោលស៊ីម៉ង់ត៍ដែលបោះព្រំដីនោះ ត្រូវបានគេដកផ្តួលចោលទៅលើដីស្រែ ។ ចំពោះសាក្សីផ្សេងទៀតបានបញ្ជាក់ប្រហាក់ប្រហែលគ្នាថា៖ ចំពោះរឿងហេតុនៃការដក និងបំផ្លិចបំផ្លាញបង្គោលរបងនៅលើដីទំនាស់នោះ គឺពួកខ្លួនមិនបានឃើញនោះទេ ។

- ផ្អែកតាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ចម្លើយរបស់ជនជាប់ចោទ និងចម្លើយរបស់សាក្សី ព្រមទាំងភស្តុតាងដែលមាននៅក្នុងសំណុំរឿង គឺមានភាពស៊ីសង្វាក់គ្នាដែលអាចឱ្យតុលាការជឿបានថា ជនជាប់ចោទឈ្មោះ [redacted] សុភាព ពិតជាបានទៅដក និងវាយបង្គោលរបងរបស់ឈ្មោះ [redacted] ចិត្រា ពិតមែន រីឯជនជាប់ចោទឈ្មោះ មុត វិចិត្រា គឺមិនបានទៅធ្វើការដក និងវាយបង្គោលរបងនៅថ្ងៃកើតហេតុនោះទេ ។ ថ្វីត្បិតតែ ជនជាប់ចោទឈ្មោះ [redacted] សុភាព បានឆ្លើយបដិសេធថា ខ្លួនមិនបានវាយបង្គោលរបងដូចការចោទប្រកាន់ ប៉ុន្តែចម្លើយនេះឃើញថា គ្រាន់តែជាការឆ្លើយដោះសារដើម្បីគេចវេះពីការទទួលខុសត្រូវប៉ុណ្ណោះ ។

- គ្មានពិរុទ្ធភាពគ្រប់គ្រាន់ទៅលើជនជាប់ចោទឈ្មោះ [redacted] វិចិត្រា ពីបទ៖ **ធ្វើឱ្យខូចខាតដោយចេតនា** បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤១០ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅភូមិដំណាក់ពពូល សង្កាត់កំពង់ឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២១ ។

- អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] សុភាព ធ្វើឡើងដោយចេតនា ហើយអំពើនេះបានធ្វើឱ្យខូចសណ្តាប់ធ្នាប់សង្គម សន្តិសុខ របៀបរៀបរយសាធារណៈ និងប៉ះពាល់ទៅដល់ទ្រព្យសម្បត្តិរបស់អ្នកដទៃ ដែលត្រូវបានច្បាប់ការពារ និងតំរូវឱ្យផ្តន្ទាទោស ។

- មានពិរុទ្ធភាពគ្រប់គ្រាន់ទៅលើជនជាប់ចោទឈ្មោះ [redacted] សុភាព ពីបទ៖ **ធ្វើឱ្យខូចខាតដោយចេតនា** បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤១០ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅភូមិដំណាក់ពពូល សង្កាត់កំពង់ឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២១ ។

- ជនជាប់ចោទឈ្មោះ [redacted] សុភាព មិនធ្លាប់មានការផ្តន្ទាទោសពីមុន ចំណែកឯទោសដែលតុលាការនឹងប្រកាសចំពោះជនជាប់ចោទនោះ គឺជាទោសដាក់ពន្ធនាគារដែលមានរយៈពេលតិចជាង ០៥ (ប្រាំ) ឆ្នាំ ។ ហេតុនេះ គប្បីតុលាការពិចារណាពីការព្យួរទោសធម្មតា តាមបញ្ញត្តិមាត្រា១០៦ និងមាត្រា១០៧ នៃក្រមព្រហ្មទណ្ឌ ។

**២.** ចំពោះផលប្រយោជន៍ផ្នែករដ្ឋប្បវេណី តុលាការយល់ឃើញថា ៖

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចិត្រា បានបញ្ជាក់ថា ៖ នៅក្នុងរឿងហេតុនេះ ខ្លួនសូមទាមទារសំណងខូចខាត និងជម្ងឺចិត្តសរុបចំនួន ៤០.០០០.០០០ (សែសិបលាន) រៀល ។

- តាមការបញ្ជាក់របស់ដើមបណ្តឹងរដ្ឋប្បវេណី និងការពិនិត្យទៅលើភស្តុតាង តុលាការនឹងធ្វើការពិចារណាពីសំណងនៃការខូចខាត ទៅតាមទំហំនៃការខូចខាតជាក់ស្តែង ដែលដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចិត្រា បានទទួលរង ។



Scanned with CamScanner

## ហេតុដូច្នេះសម្រេច

១. ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] សុភាព ភេទស្រី (មានអត្តសញ្ញាណដូចខាងលើ) ដាក់ពន្ធនាគារ ចំនួន ០៦ (ប្រាំមួយ) ខែ តែទោសនេះ ត្រូវអនុវត្តព្យួរធម្មតា ពីបទ៖ ធ្វើឱ្យខូចខាតដោយចេតនា បទល្មើសព្រហ្មទណ្ឌ ដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤១០ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅភូមិដំណាក់ពពូល សង្កាត់កំពង់ឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២១ ។ (ក្រៅឃុំ)

២. ឱ្យជនជាប់ចោទឈ្មោះ [redacted] វិចិត្រា ភេទប្រុស (មានអត្តសញ្ញាណដូចខាងលើ) បានរួចខ្លួនពីបទ៖ ធ្វើឱ្យខូចខាតដោយចេតនា បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសបញ្ញត្តិតាមមាត្រា៤១០ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅក្នុងភូមិដំណាក់ពពូល សង្កាត់កំពង់ឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី០១ ខែមិថុនា ឆ្នាំ ២០២១ ។ (ក្រៅឃុំ)

៣. បង្គាប់ឱ្យឈ្មោះ [redacted] សុភាព ភេទស្រី (មានអត្តសញ្ញាណដូចខាងលើ) សងការខូចខាតទៅឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចិត្រា ភេទប្រុស (មានអត្តសញ្ញាណដូចខាងលើ) ចំនួន ២.០០០.០០០ (ពីរលាន) រៀល ។ ការទាមទារលើសពីនេះ ត្រូវច្រានចោល ។

សាលក្រមនេះ ជំនុំជម្រះជាសាធារណៈដោយកំបាំងមុខជនជាប់ចោទឈ្មោះ [redacted] វិចិត្រា / ចាត់ទុកថាចំពោះមុខជនជាប់ចោទឈ្មោះ [redacted]សុភាព / ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចិត្រា និងប្រកាសជាសាធារណៈនៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៣ ។ ភាគី មានសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។/.

| ក្រឡាបញ្ជី | ចៅក្រមជំនុំជម្រះ |
|---|---|
| ហត្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| [redacted] | [redacted] |

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃអង្គារ ៥កើត ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

ខេត្តកំពង់ឆ្នាំង,ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៣

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ចៅក្រមជំនុំជម្រះ**

[redacted]